ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
# រយៈពេល ៣ ឆ្នាំ
# (២០០៨-២០១០)

| | | |
|---|---|---|
| សហគមន៍នេសាទ | : | បាក់ភ្នំ |
| ភូមិ | : | បាក់ភ្នំ |
| ឃុំ | : | អំពិលទឹក |
| ស្រុក | : | កំពង់ត្រឡាច |
| ខេត្ត | : | កំពង់ឆ្នាំង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

| | | |
|---|---|---|
| សហគមន៍នេសាទ | : | បាក់ត្នោត |
| ភូមិ | : | បាក់ត្នោត |
| ឃុំ | : | អំពិលទឹក |
| ស្រុក | : | កំពង់ត្រឡាច |
| ខេត្ត | : | កំពង់ឆ្នាំង |

# ផែនការគ្រប់គ្រង
# តំបន់នេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **បាក់ភ្នំ** ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូង នៅថ្ងៃទី **២៥** ខែ **ឧសភា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងតំបន់នេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទបាក់ភ្នំមានទីតាំងស្ថិតនៅក្នុងភូមិ **បាក់ភ្នំ** ឃុំ **អំពិលទឹក** ស្រុក **កំពង់ត្រឡាច** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **១៨១ នាក់** ស្រីចំនួន **៩៨** នាក់ និងមានគណៈកម្មការចំនួន **១១** នាក់ ស្រីចំនួន **២** នាក់។ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន **៨០** គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ ការចុះល្បាត ផ្សព្វផ្សាយការងារសហគមន៍ ចុះបញ្ជីឈ្មោះសមាជិកសហគមន៍ រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ រៀបចំ និងធ្វើមហាសន្និបាតបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ ធ្វើការពិគ្រោះយោបល់ និងរៀបចំកិច្ចព្រមព្រៀងរបស់សហគមន៍នេសាទ គណៈកម្មការសហគមន៍នេសាទបានធ្វើរបាយការណ៍ប្រចាំខែ និងរបាយការផ្សេងៗទៀតដែលសហគមន៍បានអនុវត្ត, សហការជាមួយជំនាញជលផល និងអាជ្ញាធរភូមិ ឃុំក្នុងការចុះល្បាត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាពលរដ្ឋៈ

តាមការស្រាវជ្រាវ និងការស្រង់ស្ថិតិពីអាជ្ញាធរភូមិ ឃុំ និងព័ត៌មានដែលមានក្នុងបញ្ជីសមាជិកសហគមន៍នេសាទបានបង្ហាញនូវព័ត៌មានដូចខាងក្រោមៈ

- ប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមានចំនួន **៦២២** នាក់ ប្រុស **៣០០** នាក់ ស្រី **៣២២** នាក់ ក្នុងនោះ មានជនជាតិខ្មែរចំនួន **៦២២** នាក់
- ស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន ២០ នាក់
- ជនពិការក្នុងសហគមន៍នេសាទមានចំនួន ៤ នាក់ ស្រី ៣ នាក់
- ចាស់ជរាក្នុងសហគមន៍នេសាទមាន ១១ នាក់ ស្រី ៧ នាក់
- កុមារកំព្រាក្នុងសហគមន៍នេសាទមានចំនួន ៧០ នាក់ ស្រី ៣២ នាក់
- អ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទ មានចំនួន ១៨ នាក់ ស្រី ១៤ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធចំនួន ៦២២ នាក់

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន **១៨** នាក់ ស្រី **១១** នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន **១៤៥** នាក់ ស្រី **៧៣** នាក់ កំរិតមធ្យមសិក្សា ចំនួន **៣០** នាក់ ស្រី **៥** នាក់ ។

**ខ-មុខរបរ**

ប្រជាជនដែលរស់នៅក្នុងសហគមន៍នេសាទ **បាក់ភ្នំ** មានមុខរបរជាច្រើនដែលរួមមានដូចខាងក្រោមៈ

- ធ្វើនេសាទ : ៨០គ្រួសារ
- ធ្វើស្រែប្រាំង : ១០៦ គ្រួសារ ទំហំ ៤៨ ហិកតា
- ត្បាញកន្ទេលកក់មូល : ៩០គ្រួសារ
- ត្បាញកន្ទេលកក់ជ្រុង : ១០គ្រួសារ
- ម៉ាស៊ីនកិនស្រូវ : ៥ គ្រួសារ
- ម៉ាស៊ីនបោកស្រូវ : ១ គ្រួសារ
- ដាំបន្លែ : ៣០ គ្រួសារ ទំហំ ៧ ហិកតា
- ជាងផ្ទះ : ៥ គ្រួសារ
- ជាងទូក : ៥ គ្រួសារ
- លក់ដូរ : ៣ គ្រួសារ
- ជួលគោយន្ត ភ្ជួរដី : ២ គ្រួសារ
- កាត់ដេរ : ៣៨ នាក់
- អ្នកស៊ីឈ្នួលគេ : ២០គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ **បាក់ភ្នំ** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទលេខ **១៩** ក្នុងដែននេសាទទឹកសាប ។

កន្លែងនេសាទសហគមន៍ **បាក់ភ្នំ** មានទំហំ **១៧៩** ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

ដែលមានព្រំប្រទល់ :

- ខាងជើងទល់នឹង **សហគមន៍នេសាទខ្នាគ្របឹម**
- ខាងត្បូងទល់នឹង **សហគមន៍នេសាទវាំលស្បូវ**
- ខាងកើតទល់នឹង **ទន្លេកប៉ាល់**
- ខាងលិចទល់នឹង **សហគមន៍នេសាទព្រែកគន្លង**

## ៩. ដែននេសាទ

កន្លែងនេសាទសហគមន៍ **បាក់ភ្នំ** មានបឹងចំនួន **១** ព្រែកចំនួន **២** ដោយមិនមានប្រឡាយ ត្រពាំង និងបឿ

- បឹង **វែង** ទំហំ ៣០ x ៣០០ម នេសាទពីខែ តុលា ដល់ខែ ឧសភា
- ព្រែក **តាកំ** ប្រវែង ៣ x ១៥០ម នេសាទពីខែ វិច្ឆិកា ដល់ខែ មករា
- ព្រែក **តាព្រឿង** ប្រវែង ៣ x ១១០ម នេសាទពីខែ តុលា ដល់ខែ មីនា
- ព្រៃលិចទឹក **បឹងវែង** មានចំនួនប្រហែល ២ហ.ត
- ព្រៃលិចទឹកមេទឹក **តាកំ**
- ព្រៃលិចទឹកមេទឹក **តាយ៉ែម**
- ព្រៃលិចទឹកមេទឹក **តាម៉ៅ**
- ព្រៃលិចទឹកមេទឹក **យាយអ៊ិន**
- ព្រៃលិចទឹកមេទឹក **កន្លែងស្មៅ**
- ព្រៃលិចទឹកមេទឹក **តាសេកជ្រុំ**

## គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកន្លែងអភិរក្សបានធ្វើការពិភាក្សារវាងគណៈកម្មការសហគមន៍នេសាទ និងសមាជិកសហគមន៍នេសាទ **បាក់ភ្នំ** បានសម្រេចជ្រើសរើយកចំនុចបឹងវែងជាកន្លែងអភិរក្សត្រីមេពូជ ដែលមានទំហំ ១០០ម x ១០០ម x ១ម ។

## ឃ. ធនធានជលផល

ផ្អែកលើលទ្ធផលនៃការពិភាក្សាពីធនធានជលផលនៅក្នុងកន្លែងនេសាទសហគមន៍ **បាក់ភ្នំ** បង្ហាញឱ្យឃើញថាធនធាន ត្រី វារីសត្វ វារីរុក្ខជាតិ និងព្រៃលិចទឹក បានថយចុះគួរឱ្យកត់សំគាល់។ គណៈកម្មការសហគន៍នេសាទ និងសមាជិកសហគមន៍នេសាទក្រោយពីបានធ្វើការពិភាក្សារួច ពួកគាត់បានយល់កាន់តែច្បាស់ពីការបាតបង់ធនធានជលផលនេះ ដែលបណ្តាលមកពីខ្វះការចូលរួមគ្រប់គ្រងពីប្រជានេសាទ ការយល់ដឹងពីច្បាប់នូវមានកំរិត និងការប្រព្រឹត្តបទល្មើសនេសាទគ្រប់ប្រភេទ។ ដូច្នេះហើយទើបពួកគាត់យល់ថាការធ្វើផែនការគ្រប់គ្រងរបស់សហគមន៍នេសាទមានសារៈសំខាន់ណាស់។

### តារាងប្រភេទធនធានជលផល

**តារាង ១:**

| ត្រី | | | វារីសត្វ | | | វារីរុក្ខជាតិ | | | ព្រៃលិចទឹក | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះត្រី | កើន | ថយ | វារីសត្វ | កើន | ថយ | វារីរុក្ខជាតិ | កើន | ថយ | ព្រៃលិចទឹក | កើន | ថយ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ត្រីរ៉ស់ | | ✓ | កង្កែប | | ✓ | កំផ្លោក | ✓ | | រាំង | | ✓ |
| ក្រាញ់ | | ✓ | គីង្គក់ | | ✓ | កំពឹងពួយ | ✓ | | ភ្កុំភ្លៀង | | ✓ |
| កញ្ជុះ | | ✓ | ហ៊ីង | | ✓ | កញ្ចៀត | | ✓ | ភ្នែកត្រី | | ✓ |
| ឆ្តោ | | ✓ | កន្ធៀទូក | | ✓ | ព្រលិត | ✓ | | ច្រកែង | | ✓ |
| កំភ្លាញ | ✓ | | ខ្ជង | ✓ | | ត្រកួន | ✓ | | ផ្ទាល | | ✓ |
| កំភ្លៀវ | | ✓ | ខ្ចៅ | ✓ | | ជន្ទល់ភ្នំ | ✓ | | ខ្នាយមាន់ | | ✓ |
| ឆ្លូញ | | ✓ | ក្តាម | ✓ | | សារ៉ាយ | ✓ | | តាអូ | | ✓ |
| ច្រវាស្លឹកឫស្សី | ✓ | | កន្ធាយ | | ✓ | ច្រាច់ | ✓ | | ទានព្រៃ | ✓ | |
| ត្រីច្រកែង | | ✓ | អណ្តើក | | ✓ | កន្តោឡេត | ✓ | | រញ្ជៀវ | | ✓ |
| លិញ | ✓ | | ពស់ព្រលិត | | ✓ | ស្លាបច្រវ៉ា | ✓ | | ថ្មើមអណ្តើក | | ✓ |
| ស្លាត | | ✓ | ពស់ ថ្លាន់ | | ✓ | កន្ទ្រាំងហែ | ✓ | | ត្រសេក | | ✓ |
| ក្រុះ | ✓ | | ពស់ ខៀវ | | ✓ | ស្លង | | ✓ | បបួយ | | ✓ |
| រៀល | ✓ | | ពស់ ទ្រង់រនាម | | ✓ | ឈូក | | ✓ | អញ្ចាញ | | ✓ |
| ក្អី | | ✓ | ពស់ វែកក្របី | | ✓ | រំចង់ | | ✓ | ខ្នាយមាន់ | | ✓ |
| គល់រាំង | ✓ | | ពស់ វែស្រងែ | | ✓ | ម្អម | | ✓ | ច្រកែង | | ✓ |
| កន្ទ្រប់ | | ✓ | ពស់ ដំបូក | | ✓ | ត្រគាត | | ✓ | បន្លាស្អិត | | ✓ |
| ឆ្លាំង | ✓ | | ពស់ ចាន់ល្មម | | ✓ | ស្មៅបារាំង | | ✓ | បនាឃ្លេ | | ✓ |
| អណ្តែង | ✓ | | ពស់ថ្នាអន្ទ្យោង | | ✓ | វល្លិត្រអើក | ✓ | | កណ្តាប់ចង្កេ | | ✓ |
| ស្រកាក្តាម | ✓ | | ពស់ស្រការចាស់ | | ✓ | វល្លិ ដូង | | ✓ | ចង្កូមក្រពើ | | ✓ |
| ក្រម៉ម | | ✓ | ពស់ សាំងសឿ | | ✓ | វល្លិ ត្រី | | ✓ | ស្នោ | | ✓ |
| កំពិស | | | ពស់សាំឡាំង | | ✓ | វល្លិ សន្ទឹម | | ✓ | កាពៅ | | ✓ |
| | | | ពស់ ដែកចា | | ✓ | វល្លិ ឡូត | | ✓ | កំព្រៀម | | ✓ |
| | | | ពស់ដី | | ✓ | វល្លិ ជុយ | ✓ | | ឆ្អឹងពស់ | | ✓ |
| | | | ពស់សំលាប់កង្កែប | | ✓ | វល្លិ តាជីត | ✓ | | ប្របាច | | ✓ |
| | | | ភេ | | ✓ | វល្លិ តាលីង | | ✓ | ត្រស់ | | ✓ |
| | | | | | ✓ | | | | កប្បាសព្រៃ | | ✓ |
| | | | | | ✓ | | | | ភ្នំភ្នាង | | ✓ |
| | | | | | ✓ | | | | ថ្ងាន់ទឹក | | ✓ |
| | | | | | ✓ | | | | បន្លាយូន | | ✓ |

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

តាមការប៉ាន់ប្រមាណចំនួនអ្នកនេសាទដែលធ្វើការនេសាទនៅក្នុងកន្លែងនេសាទសហគមន៍មានដូចខាងក្រោមៈ

- អ្នកនេសាទសរុបដែលរស់នៅក្នុងសហគមន៍មានចំនួន **១៨១** នាក់ ស្រី **៩៨** នាក់ ក្នុងនោះមានៈ
  - អ្នកនេសាទជាសមាជិកសហគមន៍នេសាទ **១៥០** នាក់ ស្រី **៥០** នាក់
  - អ្នកនេសាទមិនទាន់ចុះឈ្មោះជាសមាជិកសហគមន៍នេសាទ **៦០** នាក់ ស្រី **២០** នាក់។
- អ្នកនេសាទដែលមកពីភូមិផ្សេងមានចំនួនប្រហែល **៣០** នាក់ ស្រី **១០** នាក់។

តាមរយៈការរកឃើញតួរលេខនៃចំនួនអ្នកនេសាទដែលធ្វើការនេសាទនៅក្នុងកន្លែងនេសាទសហគមន៍ បានផ្តល់ជាគំនិតដល់គណៈកម្មការសហគមន៍នេសាទដែលបានចូលរួមធ្វើផែនការ ឱ្យគិតអំពីការងារដែលត្រូវធ្វើនៅពេលខាងមុខ ដូចជាៈការផ្សព្វផ្សាយបន្តដើម្បីទទួលបានសមាជិកសហគមន៍នេសាទបន្ថែម និងការប្រមូលភាគទានសមាជិកសហគមន៍ និងអ្នកនេសាទដែលមកពីខាងក្រៅសម្រាប់បម្រើការងារសហគមន៍។

### ៦. ឧបករណ៍នេសាទ

**សមាជិកសហគមន៍នេសាទៈ**

**- មងៈ** ១០នាក់ x ២ដៃ-៨០ម/គ្រួសារ ជាមធ្យម ចាប់បានជាមធ្យម ១គ.ក្រ ពេលចេញនេសាទម្តង រក៣០ថ្ងៃ/ខែ ពីខែ៩-១១។ ៦០នាក់ x ២ដៃ x ៣០គ.ក្រ ៦ថ្ងៃ/ខែ ៣ខែ/ឆ្នាំ ១២-០២, ៦០ x ២ x ៣០ x ៦ x ៣ = ៦០០០ x ១៨ = ៦៤៨០០, ១០នាក់ x ២ដៃ/គ្រួសារ x ១ x ៣០ថ្ងៃ/ខែ x ៣ខែ = ២០ x ៩០= ១៨០០+ ៦៤៨០០= ៦៦.៦០០ គក្រ។

**- សន្ទូចរនងៈ**

៣០នាក់ x ១សាង-២០០ផ្លែ ១គ.ក្រ/ថ្ងៃ ១ខែ ១៥ថ្ងៃ ១ឆ្នាំ ២ខែ-៩-១០, ៣០ x ១ x ១៥ x ២ = ៦០

**- នាមវាតដៃៈ** ២០គ្រួសារ-១០នាម-១នាមប្រើ២នាក់១គ.ក្រ/ថ្ងៃ ៤ថ្ងៃ ១ខែ ពីខែ ៧ ដល់ ៩ និង១២-២ ៥ខែ/ឆ្នាំ ២០ x ១ x ៤ x ៣ = ២៤០(ពីខែ ៧-៩), ២០ x ១ x ៤ x ៥ = ៤០០ (ពីខែ ១២-២)

**- សៃយឺនកំពិលៈ** ៤នាក់ ១៥សៃយឺន ម្តង ១,៥គ.ក្រ ១៥ថ្ងៃ/ខែ ១ខែ១ឆ្នាំ នៅខែ១០

**- សំណាញ់ៈ** ៥នាក់ ១សំណាញ់ម្នាក់ រកបាន១គ.ក្រម្តង រក៥ថ្ងៃ/ខែ ពីខែ ១-១២។

**- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទៈ**

**ប្រភេទ និងចំនួនឧបករណ៍នេសាទ**

**<u>តារាង ២ៈ</u>**

| ប្រភេទឧបករណ៍ | ឯកត្តា | ចំនួនឯកត្តា/គ្រួសារ | ចំនួនគ្រួសារប្រើប្រាស់ | ទំហំ, ប្រវែង | ពេលវេលាប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|
| មង | ដៃ | ២ | ១១០ | ២២០ | ខែតុលា-កុម្ភៈ |
| សន្ទូចរនង | សាង | ១ | ៣០ | ៣០ | ខែតុលា-វិច្ឆិកា |
| នាមវាតដៃ | វង់ | ១ | ១០ | ១០ | ខែកក្កដា-កុម្ភៈ |

| | | | | | |
|---|---|---|---|---|---|
| សៃយឺនកំពិស | គ្រឿង | ៤ | ៤ | ១៦ | ខែតុលា |
| សំណាញ់ | វង់ | ១ | ៥ | ៥ | ខែមករា-ធ្នូ |
| តុម | គ្រឿង | ១ | ១៥ | ១៥ | ខែឧសភា-មិថុនា |

**បញ្ជាក់:**

* មង ១ដៃប្រវែង ៨០ម

* សន្ទូចរនង ១ សាង មានចំនួន ២០០ផ្លែ

* នាមវាតដៃ ប្រើ ១វង់ពីរនាក់ ។

**ប្រភេទ និង ចំនួនទូក-កាណូត**

**តារាង ៣:**

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកគ្មោត | ១០ | ១០០ គ.ក្រ | - |
| ទូកឈើ | ១០ | ៣០០គ.ក្រ | - |
| កាណូត | ២០ | ៥៥-១០០០គ.ក្រ | ៥០០-១០០០គក្រ |

- **ឧបករណ៍នេសាទ និងទូក-កាណូតរបស់អ្នកនៅក្នុងសហគមន៍ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ**

**ប្រភេទ និង ចំនួនឧបករណ៍នេសាទ**

**តារាង ៤:**

| ប្រភេទឧបករណ៍ | ឯកត្តា | ចំនួនឯកត្តា/គ្រួសារ | ចំនួនគ្រួសារប្រើប្រាស់ | ទំហំ, ប្រវែង | ពេលវេលាប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|
| មង | ដៃ | ២ | ៣០ | ៦០ | ខែធ្នូ-កុម្ភៈ |
| សន្ទូចរនង | សាង | ១ | ៣០ | ៣០ | ខែតុលា-វិច្ឆិកា |
| នាមវាតដៃ | វង់ | ១ | ១០ | ១០ | ខែកក្កដា-កុម្ភៈ |
| សំណាញ់ | វង់ | ១ | ៤ | ៤ | ខែមករា-ធ្នូ |

**បញ្ជាក់:**

- មង ១ដៃប្រវែង ៨០ម

- សន្ទូចរនង ១ សាង មានចំនួន ២០០ផ្លែ

- នាមវាតដៃ ប្រើ ១វង់ពីរនាក់ ។

**ប្រភេទ និង ចំនួនទូក-កាណូត**

**តារាង ៥:**

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកគ្មោត | ៥ | ១០០ គ.ក្រ | |
| ទូកឈើ | ៤ | ៣០០គ.ក្រ | |
| កាណូត | ១៣ | ៥៥-១០០០គ.ក្រ | ៥០០គក្រ-១តោន |

- **អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ:**

ប្រភេទ និង ចំនួនឧបករណ៍នេសាទ

**តារាង ៦:**

| ប្រភេទឧបករណ៍ | ឯកត្តា | ចំនួនឯកត្តា/គ្រួសារ | ចំនួនគ្រួសារប្រើប្រាស់ | ទំហំ, ប្រវែង | ពេលវេលាប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|
| មង | ដៃ | ៥ | ៣០ | ១៥០ | ១២-២ |
| សន្ទូចរនង | សាង | ១ | ៣ | ៣ | ៦-៨ |

- មង ១ដៃប្រវែង ៧០ម

- សន្ទូចរនង ១ សាង មានចំនួន ៦០០ផ្លែ

ប្រភេទ និង ចំនួនទូក-កាណូត

**តារាង ៨:**

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកឈើ | ១០ | ៣០០គ.ក្រ | - |
| កាណូត | ៥ | ៣០០គ.ក្រ | ៥០០គក្រ-១តោន |

- **តារាងសង្ខេបប្រភេទឧបករណ៍នេសាទដែលប្រើប្រាស់សរុបក្នុងសហគមន៍នេសាទ បាក់ភ្នំ**

**តារាង ៩:**

| ប្រភេទឧបករណ៍ | អ្នកចូលជាសមាជិក | មិនមែនជាសមាជិក | អ្នកក្រៅសហគមន៍ | រដូវបើក | រដូវបិទ | ចំនួនឧបករណ៍សរុប |
|---|---|---|---|---|---|---|
| មង (ដៃ) | ២២០ | ៦០ | ១៥០ | | | ៥៣០ |
| សន្ទូចរនង (សាង) | ៣០ | ៣០ | ៣ | | | ៦៣ |
| នាមវាតដៃ (វង់) | ១០ | ១០ | ០ | | | ២០ |
| សៃយឺនកំពិស (គ្រឿង) | ១៦ | ០ | ០ | | | ១៦ |
| សំណាញ់ (វង់) | ៥ | ៤ | ០ | | | ៩ |
| តុម (គ្រឿង) | ១៥ | ០ | ០ | | | ១៥ |

**គ. ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ**

**តារាង ១០:**

| ប្រភេទឧបករណ៍ | ផលចាប់តាមប្រភេទឧបករណ៍គិតជាមធ្យមប្រចាំឆ្នាំ *គិតជា គក្រ)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| មង | ៣០០០ គក្រ | ៣៥០០០ គក្រ | ៣៨០០០ គក្រ |
| សន្ទូចរនង | ២០០ គក្រ | ៦០០ គក្រ | ៨០០ គក្រ |
| នាមវាតដៃ | ១៥០ គក្រ | ២០០០ គក្រ | ២១៥០ គក្រ |
| សៃយឺនកំពិស | ០ | ៤០០ គក្រ | ៤០០ គក្រ |
| សំណាញ់ | ៣៥០ គក្រ | ៤៥០ គក្រ | ៨០០ គក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនវិស័យ

សហគមន៍នេសាទ **បាក់ភ្នំ** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវដំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

**តារាង ១១:**

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹងវែង | ខែ មីនា-មេសា | អង្រុត | - | ២០ | ២០នាក់ |
| | ខែ តុលា-ឧសភា | សន្ទូចរនង | ១០០ផ្លែ/នាក់ | ១០០០ផ្លែ | ១០នាក់ |
| | ខែ តុលា-ឧសភា | មង | ៦០ម៉ែត្រ/នាក់ | ៣០០ម៉ែត្រ | ៥នាក់ |
| | ខែ តុលា-ឧសភា | សំណាញ់ | ១វង់/នាក់ | ២វង់ | ២នាក់ |

#### គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

**តារាង ១២:**

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃខែ ឆ្នាំចាប់ផ្តើម | ថ្ងៃខែ ឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងវែង | ៩ហិកតា | ១០០x១០០x១ម | ស្តារដោយគ្រឿងចក្រ | ខែឧសភា ២០០៩ | ខែកក្កដា ២០០៩ | ៦.០០០ដុល្លា |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

**តារាង ១៣:**

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងវែង | ១ហត | ត្រីមេពូជ | -បោះផ្លាក<br>-ដាក់ដែក<br>-លួស<br>-បោះបង្គោល និងផ្សព្វផ្សាយ | ខែសីហា ២០០៨ | ខែធ្នូ ២០១០ | ២០០០ដុល្លា |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម:

**តារាង ១៤:**

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំនិងការពារ | សកម្មភាព | ថ្ងៃខែ ឆ្នាំចាប់ផ្តើម | ថ្ងៃខែ ឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ដាំព្រៃលិចទឹកនៅមេទឹកតាយ៉ែម | ៣,៥ហត | រាំង និងត្រស់ | បណ្តុះកូនឈើ ផ្សព្វផ្សាយ និងដាំ | ខែ មករា ២០០៨ | ខែ មិថុនា ២០០៨ | ១០០០ដុល្លា |

## គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោម:

**តារាង ១៥:**

| ប្រភេទវារីវប្បកម្មប៉ែ | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ | ៦៥ | ត្រីប្រា និងអណ្តែង | ១៣០.០០០កូនត្រី | ខែ ធ្នូ ២០០៨ | ខែសីហា ២០០៩ |

## គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

**តារាង ១៦:**

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រមូលថវិកា | ខែ កុម្ភៈ ២០០៨ | ខែ មីនា ២០០៨ | ៩០.៥០០៛ | |
| ភាគទានប្រចាំឆ្នាំ | ប្រមូលថវិកា | ខែ មេសា ២០០៨ | ខែ ឧសភា ២០០៨ | ១៨១.០០០៛ | |
| ជំនួយសប្បុរសជន និងអង្គការនានា | ភូមិ និងការអភិវឌ្ឍន៍ | ២០០៧ | ២០០៧ | ១០០០ដុល្លា | |

## គ-៧ ផែនការសុខភាព និងអានាម័យ

**តារាង ១៧:**

| ប្រភេទសកម្មភាព | ចំនួនគ្រួសារ | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| ពាងយក្ស | ២០ | ២០ពាង | ២០០០ ដុល្លារ | ខែឧសភា ២០០៨ | ខែកក្កដា២០០៩ |
| ផ្តល់ធុងចម្រុះទឹកស្អាត | ៤០ | ៤០ធុង | ៤០០ ដុល្លារ | ខែមករា ២០០៨ | ខែមករា ២០០៩ |

## គ-៨ ផែនការទ្រទ្រង់ជីវភាព

**តារាង ១៨:**

| ប្រភេទសកម្មភាព | ចំនួនគ្រួសារ | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| ផ្តល់គ្រាប់ពូជបន្លែ | ៥០ | ១០ ដុល្លា | ៥០០ ដុល្លា | ខែវិច្ឆិកា ២០០៨ | ខែកក្កដា២០០៨ |
| ផ្តល់មាន់ចិញ្ចឹម | ៣០ | ៩០ ក្បាល | ៣៦០ ដុល្លារ | ខែវិច្ឆិកា ២០០៨ | ខែធ្នូ ២០០៨ |
| ផ្តល់ជ្រូក | ៣០ | ៣០ ក្បាល | ៩០០ ដុល្លារ | ខែវិច្ឆិកា ២០០៩ | ខែធ្នូ ២០០៩ |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែល ទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរក ថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួល បានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រង សហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធ សំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ បាក់ត្នោត រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

**តារាង ១៩:**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ចុះត្រួតពិនិត្យការប្រើប្រាស់ ឧបករណ៍នេសាទនៅបឹងវែង | ការធ្វើនេសាទនៅក្នុងបឹងធំមិនហួសកំរិតឡើយ | ៦០០ ដុល្លា | -សហគមន៍<br>-អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងរដ្ឋាភិបាល | ខែមេសា-ឧសភា ២០០៨ | ខែមេសា-ឧសភា ២០១០ | |
| ២. ការកែលំអដែននេសាទ | ស្តារបឹងវែងទំហំ ១០០x១០០x១ម | កន្លែងដែលស្តារក្នុងបឹងមិនរីងនៅរដូវប្រាំង | ៦០០០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែឧសភា ២០០៩ | ខែកក្កដា ២០០៩ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | បោះផ្លាក ដាក់ដែកលួស បោះបង្គោល និងផ្សព្វផ្សាយ | មានតំបន់អភិរក្សទំហំចំនួន ១ហតនៅក្នុងបឹងវែង | ២០០០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែសីហា ២០០៨ | ខែធ្នូ ២០១០ | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាំព្រៃលិចទឹក នៅមេទឹកតាយ៉ែម | ទំហំដី៣.៥ហតនឹងមានព្រៃរាំង និងត្រស់ដុះឡើងវិញ | ១០០០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែមករា ២០០៨ | ខែមិថុនា ២០០៨ | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីតាមស្រះ | ស្រះក្នុងភូមិចំនួន៦៥មានចិញ្ចឹមត្រីប្រា និងអណ្តែង | ១៥០០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែធ្នូ ២០០៨ | ខែសីហា ២០០៩ | |
| ៦. ផែនការរកប្រាក់ចំណូលសហគមន៍ | ប្រមូលថវិកាពីសមាជិកស.ន | សមាជិកស.ន នឹងបង់ប្រាក់គ្រប់ចំនួនទាំងមាជិកភាព និងប្រចាំឆ្នាំ | គ្មាន | -គណៈកម្មការស.ន និងប្រធានភូមិ | ខែកុម្ភៈ ២០០៨ | ខែឧសភា ២០០៨ | |
| ៧. ផែនការសុខភាព និង | ផ្តល់ពាងយក្ស និងធុង | គ្រួសារដែលក្រីក្រ និងស្ត្រី | ២៤០០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែមករា | ខែកក្កដា | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| អនាម័យ | ចម្រោះទឹក | មេម៉ាយនឹងបានទទួលពាងទឹកយក្ស និងធុងទឹកចម្រោះប្រើប្រាស់ចំនួន ៦០គ្រួសារ | | | ២០០៨ | ២០០៩ | |
| ៨. ផែនការទ្រទ្រង់ជីវភាព | -ចិញ្ចឹមមាន់<br>-ចិញ្ចឹមជ្រូក និងគ្រាប់ពូជបន្លែ | សមាជិកសហគមន៍ចំនួន១១០គ្រួសារ នឹងបានទទួលមាន់ ជ្រូក និងគ្រាប់ពូជបន្លែយកមកចញ្ចឹម និងដាំ។ | ១៧៦០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែវិច្ឆិកា ២០០៨ | ខែធ្នូ ២០៩ | |

| សកម្មភាព | តារាងកម្មវិធីការងារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឆ្នាំ ២០០៨ | | | | | | | | | | | | ឆ្នាំ ២០០៩ | | | | | | | | | | | | ឆ្នាំ ២០១០ | | | | | | | | | | | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | | | | ■ | ■ | | | | | | | | | | | ■ | ■ | | | | | | | | | | | ■ | ■ | | | | | | | |
| ២. ការកែលំអដែននេសាទ | | | | | | | | | | | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍ | | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧. ផែនការទ្រទ្រង់សុខភាព និងអនាម័យ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | |
| ៨. ផែនការទ្រទ្រង់ជីវភាព | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | |

បានឃើញ និងបញ្ជូនមក

លោកនាយសង្កាត់រដ្ឋបាលជលផល.......

នាយសង្កាត់រដ្ឋបាលជលផល..................

.......ថ្ងៃទី...10......ខែ...9......ឆ្នាំ ២០០8

លេខ :............

បានឃើញ

មេឃុំ...........

.......ថ្ងៃទី...10...ខែ....9....ឆ្នាំ ២០០8

លេខ ..........

.......ថ្ងៃទី....9....ខែ....9....ឆ្នាំ ២០០8

ប្រធានគណៈកម្មការសហគមន៍នេសាទ

លេខ :02......

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ..........ឆ្នាំ ២០០

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ"

.......ថ្ងៃទី..27...ខែ..11...ឆ្នាំ ២០០8

**នាយអធិការដ្ឋានរដ្ឋបាលជលផល**.........

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋានរដ្ឋបាលជលផល..........

.......ថ្ងៃទី..01..ខែ..10...ឆ្នាំ ២០០8

**នាយខណ្ឌរដ្ឋបាលជលផល**..........